# ធ្វើជាប្រជាពលរដ្ឋសកម្មមួយនៅការប្រជុំក្រុមប្រឹក្សាសាលា

អ្នកអាចជួយបង្កើតគោលនយោបាយទៅក្នុងសាលាក្នុងតំបន់របស់អ្នកបាន ដោយទំនាក់ទំនងគំនិតរបស់អ្នកទៅ សម៉ាជិកក្រុមប្រឹក្សាសាលារបស់អ្នក។

**ទទួលយករបៀបវារៈ។** របៀបវារៈធ្វើឡើងសំរាប់សាធារណៈយ៉ាងហោចណាស់ ២៤ ម៉ោង មុនប្រជុំក្រុមប្រឹក្សាសាលា។ អ្នកអាចស្វែងរករបៀបវារៈនៅលើវ៉ិបសាយសាលាក្នុងតំបន់។

**ត្រៀមនិយាយ**នៅអង្គប្រជុំក្រុមប្រឹក្សា។ អង្គប្រជុំទៀងទាត់របស់ក្រុមប្រឹក្សាសាលា ជាធម្មតារួមមាន ឱកាសសំរាប់យោបល់សាធារណៈ។ ក្រុមប្រឹក្សាជាច្រើន ផ្តល់ក្រដាសចុះហត្ថលេខាជិតផ្លូវចូលទៅបន្ទប់ក្រុមប្រឹក្សា។

**ដំណាងឲ្យក្រុមសហគមន៍**ចំពោះក្រុមប្រឹក្សាសាលា។ រាយការណ៍សកម្មភាពក្រុមប្រឹក្សាទៅក្រុមរបស់អ្នក។

**ស្វែងរកអង្គប្រជុំដែលផ្សព្វផ្សាយ**តាមទូរទស្សន៍ខ្សែកាប ឬសូមការិយាល័យក្នុងតំបន់ បើសិនជាមានតារាងអ៊ីមែលសំរាប់មនុស្សដែលម៉ានចំណូលចិត្តពត៌មានក្រុមប្រឹក្សាសាលា។

**សរសេរ** ឬទូរស័ព្ទទៅអ្នកដំណាងក្រុមប្រឹក្សាសាលារបស់អ្នក ដើម្បីឲ្យមតិរបស់អ្នកដឹងឮ។

រាល់អង្គប្រជុំក្រុមប្រឹក្សាសាលា គឺបើកសំរាប់សាធារណៈ លើកលែងតែនៅពេលប្រធានបទជា ការលក់ដូរអចលនទ្រព្យ រឿងផ្ទាល់ខ្លួន វិវាទមិនទាន់សំរេច ការចរចារកិច្ចសន្យា ឬសវនាការត្រឹមត្រូវ ។

# ការរៀបចំដូចម្តេចរបស់អ្នកដឹកនាំសាលាក្នុងតំបន់

**ក្រុមប្រឹក្សាសាលា**
បានជ្រើសរើសដោយអ្នកបោះឆ្នោតដើម្បីដាក់គោលដៅ ធ្វើគំរោងយុទ្ធសាស្ត្រ ជួលនិងត្រួតត្រាអ្នកមើលខុសត្រូវ គ្រោងថវិកាសំរាប់សាលាក្នុងតំបន់ និងបង្កើតគោលនយោបាយ។

↑

**អ្នកមើលខុសត្រូវ**
បានជួលដោយក្រុមប្រឹក្សាសាលា ដើម្បីចាត់ចែងសាលាក្នុងតំបន់។

↑

**ចាងហ្វាង**
រាយការណ៍ទៅអ្នកមើលខុសត្រូវ។ ចាត់ចែងបុគ្គលិក និងគណៈសិស្ស និងការប្រតិបត្តិប្រចាំថ្ងៃរបស់សាលា។

↑

**គ្រូ**
រាយការណ៍ទៅចាងហ្វាង។

**ការិយាល័យនៃអំបាដម៉ានអប់រំ**
**Office of the Education Ombudsman**
1110 Capitol Way S,  Suite 304
P.O. Box 40004
Olympia, WA 98504-0004

**លេខឥតគិតថ្លៃ:** 1-866-297-2597
**ទូរសារ:** (360) 586-0052

www.waparentslearn.org

ទាក់ទងការិយាល័យអំបាដម៉ានអប់រំ បើសិនជាអ្នកចង់ទទួលឯកសារនេះជាទ្រង់ទ្រាយផ្លាស់គ្នាដើម្បីបំពេញចិត្តមនុស្សអសម្ថភាព។

ការិយាល័យអំបាដម៉ានអប់រំ ផ្តល់សេវាពត៌មាន និងការណែនាំទៅសិស្សានុសិស្ស គ្រួសារ និងសហគមន៍ទាក់ទង ទៅនឹងប្រព័ន្ធអប់រំសាធារណៈ ជំរុញគ្រួសារ និងសហគមន៍ឲ្យមានទំនាក់ទំនងជាមួយការអប់រំ ហើយជួយគ្រួសារ និងសិស្សដោះស្រាយជំលោះជាមួយសាលា។






# តើសាលាក្នុងតំបន់ដំណើរការដោយរបៀបណា?
# How Does a School District Work?

ការិយាល័យនៃអំបាដម៉ានអប់រំ
Office of the Education Ombudsman

**ការណែនាំសំរាប់គ្រួសារ**
**A Guide for Families**

រដ្ឋវ៉ាស៊ីនតោន
ការិយាល័យអភិបាលរដ្ឋ
State of Washington
Office of the Governor

**Cambodian**

# មើលរូបភាពធំ

ការស្រាវជ្រាវបានបង្ហាញថា សិស្សានុសិស្សមានជោគជ័យក្នុងសាលាជាង នៅពេលឪពុកម្តាយរបស់គេដើរតួរ សកម្មផ្នែកអប់រំរបស់គេ។ ការចូលរួមជាសកម្ម ជាធម្មតាមានន័យថាជួយធ្វើលំហាត់នៅផ្ទះ ឬការទាក់ទងជាមួយ គ្រូកូនរបស់អ្នក ប៉ុន្តែការចូលរួមរបស់អ្នកអាចលើសពីការរៀនសូត្រ។ នៅពេលអ្នកមានកង្វល់ ការណែនាំ ឬសំណួរដែលទាក់ទងទៅនឹងការអប់រំកូនរបស់អ្នក វាមានប្រយោជន៍ដើម្បីយល់ ថាតើសាលា និងថ្នាក់កូនរបស់អ្នក ត្រូវទៅនឹងបណ្តាញធំនៃសាលាក្នុងតំបន់របៀបណា។ បណ្ណពាណិជ្ជកម្មនេះ ពន្យល់របៀបរចនាសម្ព័ន្ធរបស់សាលា ក្នុងតំបន់។

## សាលាក្នុងតំបន់ក្នុងរដ្ឋវ៉ាស៊ីនតោន

វ៉ាស៊ីនតោនមានប្រហែល ៣០០ សាលាក្នុងតំបន់ សាលានិមួយៗមានក្រុមប្រឹក្សាសាលាដែលបានជ្រើសរើស។ តំបន់ច្រើនអាចមានសាលាតែមួយ ឬនៅក្នុងទីក្រុងស៊ីអាថុល អាចមានរហូតដល់ ១០០ សាលា ។

## អ្នកណាជាអ្នកណានៅសាលាក្នុងតំបន់

**ក្រុមប្រឹក្សាសាលា។** ពលរដ្ឋក្នុងសាលាក្នុងតំបន់និមួយៗជ្រើសរើសសមាជិកក្រុមប្រឹក្សាសាលា។ ជាមួយគ្នានេះ សមាជិកមានពាក្យចុងក្រោយនៅលើច្បាប់ នីតិវិធី និងថវិកាសាលាក្នុងតំបន់។ ក្រុមប្រឹក្សាសាលាគ្រប់គ្រងតំបន់។

## អ្នកមើលខុសត្រូវ និងបុគ្គលិកសាលាក្នុងតំបន់

ធ្វើការជាមួយចាងហ្វាងនៅសាលានិមួយៗ ដើម្បីចាត់ចែងការងារប្រចាំថ្ងៃ នៃការអប់រំក្មេង។ ក្រុមប្រឹក្សាសាលាដឹកនាំការងាររបស់អ្នកមើលខុសត្រូវ។

| អ្នកមើលខុសត្រូវ | ក្រុមប្រឹក្សាសាលា |
|---|---|
| បានជួលដោយក្រុមប្រឹក្សាសាលា | ជ្រើសរើសដោយអ្នកបោះឆ្នោត |
| ចាត់ចែងការប្រតិបត្តិរាល់ថ្ងៃ | គ្រប់គ្រង ការណែនាំ |
| អនុវត្តន៍គោលនយោបាយ | បង្កើតគោលនយោបាយ និងគំរោង |
| អំណាចផ្តល់ដោយក្រុមប្រឹក្សាសាលា | មានអំណាច តែជាក្រុម |

# មូលដ្ឋានក្រុមប្រឹក្សាសាលា

សមាជិកក្រុមប្រឹក្សាសាលា ក៏បានហៅផងដែរថា នាយក។ មានសមាជិកប្រាំនៅក្នុងក្រុមប្រឹក្សាសាលា លើកលែងតែនៅក្នុងតំបន់ធំរបស់រដ្ឋ សាលាសាធារណៈស៊ីអាថុល ដែលក្រុមប្រឹក្សាមានសមាជិកប្រាំពីរនាក់។

សមាជិកក្រុមប្រឹក្សាសាលាៈ

- គឺបានជ្រើសរើស ដោយអ្នកបោះឆ្នោតក្នុងសាលាក្នុងតំបន់និមួយៗ រៀងរាល់រំលងមួយឆ្នាំ (លេខឆ្នាំសេស)។
- បំរើអាណត្តិតៗគ្នា។ មិនមែនតំណែងទាំងអស់បើកចំហររាល់ការបោះឆ្នោតនោះទេ។
- គឺត្រូវបង់ប្រាក់តិចតួចប្រចាំថ្ងៃក្នុងតំបន់មួយចំនួន។ ខណៈនាយក ក្នុងតំបន់ផ្សេងទៀតទទួលតែសំណងរាល់ ចំណាយ។ នេះគឺបានបញ្ចាក់ដោយច្បាប់ក្រុមប្រឹក្សា។
- ប្រហែលជាបានជ្រើសរើស “ធំទូលាយ” ឬបានជ្រើសរើសពីសង្កាត់ជាក់លាក់នៅក្នុងតំបន់។ នាយកនិមួយៗ ដំណាងឲ្យចំណូលចិត្តនៃសិស្សានុសិស្សក្នុងតំបន់ទាំងមូល។
- បំរើអាណត្តិដែលមានបួនឆ្នាំ (លើលែងនៅក្នុង ៊ំផ្សកានេ, ទាច្សមា និង វែរេតេត ដែលក្រុមប្រឹក្សាបំរើអាណត្តិ ដែលមាន ប្រាំមួយឆ្នាំ) ។

## តួរនាទីរបស់ក្រុមប្រឹក្សា

- បង្កើតចក្ខុវិស័យ និងដាក់គោលដៅសំរាប់សាលាក្នុងតំបន់
- គំរោងយុទ្ធសាស្ត្រ។
- ជួលអ្នកមើលខុសត្រូវ
- បង្កើតគោលនយោបាយទាំងមូល និងមើលថែរក្សា។
- យល់ព្រម និងការត្រួតពិនិត្យថវិការបស់តំបន់ និងគំរោងការអប់រំ។
- ដំណាងឲ្យអ្នកបោះឆ្នោត នៃសហគមន៍របស់គេ។

## តើអ្នកណាអាចជាសមាជិកក្រុមប្រឹក្សាសាលា?

តំណែងនាយកសាលា គឺបើកចំហរទៅគ្រប់មនុស្សដែលជាអ្នកបោះឆ្នោតមានក្របខ័ណ្ឌក្នុងសាលាក្នុងតំបន់។ បេក្ខជនត្រូវបំពេញការបង្ហាញហិរញ្ញវត្ថុ និងឈ្មោះការជ្រើសរើសក្រុមប្រឹក្សាសាលា។

# គ្រូ ចាងហ្វាង និងសមាជិកបុគ្គលិកផ្សេងទៀត

មនុស្សមុនដំបូងដែលអ្នកជួបនៅសាលា គឺប្រហែលជាគ្រូកូនរបស់អ្នក ជាមនុស្សជាប់ទាក់ទងដោយផ្ទាល់ និងច្រើនក្នុងការអប់រំកូនរបស់អ្នក។ គ្រូក្នុងថ្នាក់បង្រៀននិងវាយតំលៃសិស្សានុសិស្ស ដើម្បីជួយគេឲ្យឈានដល់កំរិត មាត្រដ្ឋាននៃការសិក្សា។

អ្នកគ្រប់គ្រងរបស់គ្រូ ជាចាងហ្វាងសាលា ដែលតួរនាទីរួមមានៈ ចាត់ចែងប្រតិបត្តិប្រចាំថ្ងៃរបស់សាលា និងរាល់ ធនធានមនុស្ស និងហិរញ្ញវត្ថុរបស់សាលា ដែលផ្តល់ការអភិវឌ្ឍន៍បុគ្គលិកដើម្បីបង្កើន វាយតម្លៃកម្មវិធី និងបុគ្គលិក របស់សាលា និងបង្កើតទំនាក់ទំនងជាមួយនឹងឪពុកម្តាយ និងសហគមន៍។ ឋានៈជាឪពុកម្តាយ អ្នកត្រូវបានស្វាគមន៍ ចំពោះការជួបជាមួយចាងហ្វាងសិស្សរបស់អ្នក។

បុគ្គលិកសាលា ក៏អាចរួមមាន ចាងហ្វាងជំនួយ លេខាធិការសាលា ជំនួយរបស់គ្រូ បណ្ណារក្ស អ្នកផ្តល់ឱវាទ អ្នកធ្វើការផ្គត់ផ្គង់គ្រួសារ និងអ្នកជំនួយទ្វេភាសា។

គ្រូភាគច្រើន និងនិយោជិកសាលាក្នុងតំបន់ផ្សេងទៀតជាច្រើនឋិតក្នុងសហជីបពលករ។ សហជីបចរចារជាមួយ ក្រុមប្រឹក្សាសាលា ដើម្បីបង្កើតកិច្ចសន្យាដែលផ្តល់នៅលក្ខខ័ណ្ឌការងារសំខាន់ៗ និងបង់ប្រាក់ និងធ្វើប្រតិទិន សំរាប់ថ្ងៃរៀន និងវិស្សមកាល។ និយោជិកត្រូវបានជួល ឬបញ្ឈប់ដូចដែលបានចែងក្នុងកិច្ចសន្យា ។

# ហិរញ្ញវត្ថុរបស់សាលាក្នុងតំបន់

ហិរញ្ញវត្ថុរបស់សាលាក្នុងតំបន់គឺជាប្រធានបទស្មុគស្មាញមួយ ព្រោះលុយចូលមកពីច្រើនប្រភព ហើយជាធម្មតា អាចតែចាយលើបំណងដែលជ្រើសរើសទុកជាមុន។ ឧទាហរណ៍ បើសិនជាអ្នកបោះឆ្នោតរបស់សាលាក្នុងតំបន់ យល់ព្រមការដកពន្ធដើម្បីកែបន្ទប់រៀន ក្រុមប្រឹក្សាសាលាមិនអាចសំរេចចិត្តប្រើលុយនោះដើម្បីទិញសៀវភៅ សិក្សា ឬបង់ប្រាក់ខែគ្រូទេ។

ក្រុមប្រឹក្សាសាលាយល់ព្រម ថាតើនៅទីណាខ្លះអ្នកមើលខុសត្រូវ និងបុគ្គលិកនឹងចំណាយលុយរបស់តំបន់។ របៀបក្រុមប្រឹក្សាសាលាដាក់មូលនិធិឲ្យប្រើប្រាស់ ប្រាប់អ្នកថា ក្រុមប្រឹក្សាឲ្យអ្វីដែលមានតម្លៃជាងគេ។ យល់ពី ចំណាយរបស់សាលាក្នុងតំបន់អាចឲ្យអ្នកយល់យ៉ាងច្បាស់ ពីអ្វីដែលកើតឡើងក្នុងសាលាក្នុងតំបន់របស់អ្នក ដែលនឹងជួយអ្នកផ្តល់ការណែនាំយល់ដឹងច្បាស់ទៅអ្នកតំណាងក្រុមប្រឹក្សាសាលារបស់អ្នក។

## តើសាលាក្នុងតំបន់ទទួលលុយរបស់គេពីណា?

- ៧០% មកពីរដ្ឋ។
- ១០% មូលនិធិសហព័ន្ធសំរាប់កម្មវិធីពិសេស។
- ១៦% ពន្ធទ្រព្យសម្បត្តិក្នុងតំបន់ ដែលបានយល់ព្រមដោយអ្នកបោះឆ្នោត។
- ៤% ប្រភពផ្សេងទៀតដូចជា រដ្ឋ សហព័ន្ធ ឬជំនួយឥតសំណងឯកជន។

## តើអ្នកណាសំរេចិត្តចំណាយវាដូចម្តេច?

- ក្រុមប្រឹក្សាសាលាជ្រើសរើសគោលដៅ និងអាទិភាព។
- អ្នកមើលខុសត្រូវ និងបុគ្គលិកបង្កើត/កំណត់ការចំណាយ។
- ក្រុមប្រឹក្សាសាលាយល់ព្រមថវិកាចំណាយ និងត្រួតពិនិត្យការចាយវាយ ។
- អ្នកបោះឆ្នោតមានឥទ្ធិពលលើវិធី តាមរយៈមនុស្សដែលគេជ្រើសរើសទៅជាក្រុមប្រឹក្សាសាលា។

## តើអ្វីជាការហូតពន្ធ?

ការហូតពន្ធជាមូលនិធិក្នុងតំបន់ ប្រើសំរាប់បង់ចំណាយរបស់សាលាក្នុងតំបន់។ ម្ចាស់ទ្រព្យសម្បត្តិបង់ចំណែក ដែលផ្អែកទៅលើតម្លៃអចលនទ្រព្យរបស់គេ។ លុយនោះអាចប្រើសំរាប់ការថែទាំ និងប្រតិបត្តិការណ៍ ចំណាយ បន្ថែម ឬការដឹកជញ្ជូន។

## តើអ្វីជាការបញ្ចេញប័ណ្ណប្រាក់ (ពន្ធណឺ)?

ការបញ្ចេញប័ណ្ណប្រាក់ជាវិធីមួយសំរាប់សាលាក្នុងតំបន់ដើម្បីខ្ចីប្រាក់។ វាត្រូវមានការយល់ព្រមពីអ្នកបោះឆ្នោត ដែលពន្ធអចលនទ្រព្យរបស់គេនឹងសងប្រាក់កម្ចីវិញរួមទាំងការប្រាក់។